- ដឹកនាំ សម្របសម្រួល និងគាំទ្រដល់អគ្គនាយកដ្ឋាន អង្គភាពចំណុះនានាក្នុងការអនុវត្តសកម្មភាពកំណែទម្រង់រដ្ឋបាល និងវិសហមជ្ឈការស្របតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រសួងសាមីនីមួយៗ
- ដឹកនាំ សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារកំណែទម្រង់រដ្ឋបាល និងវិសហមជ្ឈការក្នុងវិស័យ ឬកិច្ចការជាអាទិភាពរបស់ក្រសួងសាមីនីមួយៗ
- តាមដាន ត្រួតពិនិត្យជាប្រចាំលើការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិសហមជ្ឈការដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងសាមី

នីមួយៗ ស្របតាមសេចក្តីសម្រេចរួមដែលបានឯកភាពគ្នារវាងក្រសួងសាមីនីមួយៗជាមួយនឹងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.

- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារកំណែទម្រង់រិមជ្ឈជការ និងវិសហមជ្ឈការរបស់ក្រសួងសាមីនីមួយៗ ដើម្បីផ្ញើជូន គ.ជ.អ.ប. តាមការកំណត់។

យន្តការនេះត្រូវមានរបៀបរបបការងារជាទូទៅ ដូចខាងក្រោម៖

- ត្រូវមានការប្រជុំជាទៀងទាត់០១ខែម្តង និងការប្រជុំតាមការចាំបាច់ ដើម្បីដឹកនាំ សម្របសម្រួល តាមដានត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តការងារកំណែទម្រង់រិមជ្ឈការ និងវិសហមជ្ឈការដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងសាមីនីមួយៗ
- រដ្ឋមន្ត្រីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ករណីរដ្ឋមន្ត្រីអវត្តមាន ត្រូវផ្ទេរសិទ្ធិទៅឱ្យរដ្ឋលេខាធិការ ដែលជាអនុប្រធានប្រចាំការធ្វើជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- រដ្ឋមន្ត្រីអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ឬតំណាងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។

II. នៅថ្នាក់ក្រោមជាតិ៖

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកនីមួយៗត្រូវរៀបចំបង្កើត "**គណៈកម្មការដឹកនាំការងារកំណែទម្រង់**"មួយជាបន្ទាន់ ដើម្បីដឹកនាំ សម្របសម្រួលកិច្ចដំណើរការជាទូទៅនៃកម្មវិធីកំណែទម្រង់រិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម ៖

ក. រដ្ឋបាលរាជធានី

១. អភិបាល	ប្រធាន
២. អភិបាលរង ០១រូប	អនុប្រធានប្រចាំការ
៣. នាយករដ្ឋបាល	សមាជិក
៤. នាយកទីចាត់ការ និងប្រធានអង្គភាពនានានៃរដ្ឋបាលរាជធានី	សមាជិក
៥. ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៦. ប្រធានមន្ទីរផែនការ	សមាជិក
៧. ប្រធានមន្ទីរមុខងារសាធារណៈ	សមាជិក
៨. ប្រធានមន្ទីរកិច្ចការនារី	សមាជិក

៩. ប្រធានរតនាគារ	សមាជិក
១០. អភិបាលខណ្ឌ	សមាជិក

ខ. រដ្ឋបាលខេត្ត

១. អភិបាល	ប្រធាន
២. អភិបាលរង ០១រូប	អនុប្រធានប្រចាំការ
៣. នាយករដ្ឋបាល	សមាជិក
៤. នាយកទីចាត់ការ និងប្រធានអង្គភាពនានានៃរដ្ឋបាលខេត្ត	សមាជិក
៥. ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៦. ប្រធានមន្ទីរផែនការ	សមាជិក
៧. ប្រធានមន្ទីរមុខងារសាធារណៈ	សមាជិក
៨. ប្រធានមន្ទីរកិច្ចការនារី	សមាជិក
៩. ប្រធានរតនាគារ	សមាជិក

គ. រដ្ឋបាលក្រុង ស្រុក

១. អភិបាល	ប្រធាន
២. អភិបាលរង ០១រូប	អនុប្រធានប្រចាំការ
៣. នាយករដ្ឋបាល	សមាជិក
៤. ប្រធានការិយាល័យ និងប្រធានអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក	សមាជិក
៥. ប្រធានការិយាល័យផែនការ	សមាជិក
៦. ប្រធានការិយាល័យកិច្ចការនារី	សមាជិក

ទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក គឺជាលេខាធិការដ្ឋាននៃគណៈកម្មការនេះ ដែលមានតួនាទីជួយគាំទ្រផ្នែកការងាររដ្ឋបាល និងការសម្របសម្រួលកិច្ចការប្រចាំថ្ងៃរបស់គណៈកម្មការនេះ។

ដើម្បីបំពេញបាននូវតួនាទីនេះ អភិបាលរាជធានី ខេត្ត ក្រុង ស្រុកត្រូវពិនិត្យឡើងវិញនូវមន្ត្រីក្នុងរចនាសម្ព័ន្ធនៃទីចាត់ការ និងការិយាល័យនេះ ដើម្បីចាត់តាំងមន្ត្រីដែលមានលក្ខណសម្បត្តិសមស្របមួយចំនួនបន្ថែមទៀតឱ្យមកបំពេញការងារនៅទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក ដែលជាលេខាធិការដ្ឋាននៃ គណៈកម្មការនេះ។

ទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក ដែលជាលេខាធិការដ្ឋាននៃគណៈកម្មការនេះ ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់ពីអភិបាលរងដែលជាអនុប្រធានប្រចាំការនៃគណៈកម្មការនេះ។

ការចំណាយសម្រាប់ការរៀបចំកិច្ចប្រជុំរបស់គណៈកម្មការ គឺជាបន្ទុករបស់រដ្ឋបាលរាជធានី ខេត្ត

ក្រុង ស្រុកសាមី។ ដោយឡែក ការចំណាយសម្រាប់ការចុះតាមដាន ត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍នានា នៅតាមមូលដ្ឋាន គឺជាបន្ទុករបស់អង្គភាពសាមីនីមួយៗនៃសមាជិករបស់គណៈកម្មការ ។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុកត្រូវចេញសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការដឹកនាំការងារកំណែទម្រង់រាជធានី ខេត្ត ក្រុង ស្រុករបស់ខ្លួន ដែលកំណត់អំពីសមាសភាព តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មការ។

គណៈកម្មការនេះមានតួនាទី និងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួលកិច្ចដំណើរការជាទូទៅនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្របតាមច្បាប់ និងលិខិតបទដ្ឋានដែលបានកំណត់
- ដឹកនាំ សម្របសម្រួលកិច្ចដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកសាមីនីមួយៗ
- ដឹកនាំ សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ ដើម្បីសម្របសម្រួល និងកៀរគរការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍ផ្នែករដ្ឋបាល និងបច្ចេកទេសដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- សម្របសម្រួល ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សម្របសម្រួល កៀរគរការចូលរួម និងការគាំទ្រនានាពីមន្ទីរ អង្គភាពជំនាញ អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងផ្នែកឯកជនក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សម្របសម្រួលការគ្រប់គ្រង និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យនានាពាក់ព័ន្ធនឹងព័ត៌មាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រងមធ្យោបាយ ឧបករណ៍ សម្ភារ និងបរិក្ខារនានារបស់ គ.ជ.អ.ប. ដែលបានបែងចែកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រើប្រាស់សម្រាប់ការងារកំណែទម្រង់
- សម្របសម្រួល និងគាំទ្រដល់ការអនុវត្តកម្មវិធីប្រឡងប្រណាំងអំពីការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្នុងការដឹកនាំ សម្របសម្រួល ករណីមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់មន្ទីរ អង្គភាព ទីចាត់

ការ ឬថ្នាក់រដ្ឋបាលណាមួយ គណៈកម្មការត្រូវណែនាំដល់មន្ទីរ អង្គភាព ទីចាត់ការ ឬថ្នាក់រដ្ឋបាលនោះ ឱ្យចាត់ចែងអនុវត្តស្របតាមតួនាទី ភារកិច្ចដែលបានកំណត់ ដើម្បីលើកកម្ពស់សមត្ថភាព និងការទទួលខុសត្រូវរបស់ស្ថាប័ន ដោយមិនត្រូវចាត់ចែងជំនួសឡើយ ហើយត្រូវតាមដានត្រួតពិនិត្យការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នទាំងនោះ

- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់រ៉ែមជ្ឈការ និងវិសហមជ្ឈការ តាមការកំណត់ ដើម្បីរាយការណ៍ជូនគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ដើម្បីផ្ញើជូនមកលេខាធិការដ្ឋាន គ.ជ.អ.ប.។

គណៈកម្មការមានរបៀបរបបការងារ ដូចខាងក្រោម៖

- ទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន
- មានរបបប្រជុំជាទៀងទាត់០១ខែម្តង និងប្រជុំតាមការចាំបាច់ ដើម្បីដឹកនាំ សម្របសម្រួល តាមដានត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តការងារកំណែទម្រង់
- ប្រធានគណៈកម្មការ ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការ។ ករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យអនុប្រធានជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- កិច្ចប្រជុំរបស់គណៈកម្មការអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល
- ប្រធានគណៈកម្មការអាចអញ្ជើញតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ប្រធានមន្ទីរ អង្គភាពជំនាញផ្សេងៗទៀត ឬតំណាងអង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមកិច្ចប្រជុំរបស់គណៈកម្មការ តាមការចាំបាច់
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការ ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការដ្ឋានរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។
- ក្នុងករណីចាំបាច់ គណៈកម្មការអាចស្នើសុំអន្តរាគមន៍ផ្នែកបច្ចេកទេសពីលេខាធិការដ្ឋាន គ.ជ.អ.ប.។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវតាមដានត្រួតពិនិត្យការរៀបចំឡើងវិញនូវយន្តការទាំងនេះ និងធ្វើការសម្របសម្រួលលើការអនុវត្តការងារកំណែទម្រង់ ព្រមទាំងត្រូវធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីសមិទ្ធផល និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់រ៉ែមជ្ឈការ និងវិសហមជ្ឈការនេះនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនានា។

ទទួលបានសេចក្ដីណែនាំនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៨ រោچ ១២ ១ ១ ២ ១ ២ ១ ២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....សហវ.....

ប្រកាសរួម
ស្តីពី
ការផ្តល់សេវាសាធារណៈដោយនិយ័តករទូរគមនាគមន៍កម្ពុជា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី	រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩១៣/ ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៤១៦/ ៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៥០៨/ ០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ១២១៥/ ០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្ទះលេខ ៥២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២៦, មាត្រា ២៧, មាត្រា ២៨ និងមាត្រា ២៩ និងបំពេញបន្ថែមមាត្រា ២៩ ស្ពន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ ._

អនុញ្ញាតឱ្យនិយ័តករទូរគមនាគមន៍កម្ពុជា អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ និងកត់ត្រាជាចំណូលរបស់និយ័តករទូរគមនាគមន៍កម្ពុជា។

ប្រការ២ ._

សេវាសាធារណៈដែលផ្តល់ដោយនិយ័តករទូរគមនាគមន៍កម្ពុជា ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសរួមនេះ។

ប្រការ៣ ._

ចំពោះការផ្តល់លិខិតអនុញ្ញាត និងវិញ្ញាបនបត្រសម្រាប់ឆ្នាំដំបូង ការយកកម្រៃសេវាត្រូវគិតតាមរយៈពេលនៅសល់ក្នុងឆ្នាំ យោងតាមកាលបរិច្ឆេទចុះហត្ថលេខារបស់និយ័តករទូរគមនាគមន៍កម្ពុជា ដែលកំណត់ដូចខាងក្រោម ÷

- រយៈពេលនៅសល់មិនលើសពី ៦ខែ ត្រូវយកកម្រៃសេវាស្មើនឹង ៥0%(ហាសិបភាគរយ) នៃតម្លៃសេវាប្រចាំឆ្នាំ
- រយៈពេលនៅសល់លើសពី ៦ខែ ត្រូវយកកម្រៃសេវាស្មើនឹងតម្លៃសេវាប្រចាំឆ្នាំ។

ប្រការ៤ .–

ប្រកាសរួមនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិករ និងបុគ្គលពាក់ព័ន្ធ ដែលធ្វើប្រតិបត្តិការ និងធ្វើអាជីវកម្មលើវិស័យទូរគមនាគមន៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ៥ .–

ទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាសាធារណៈដែលមានចែងក្នុងប្រកាសរួមនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងសេចក្តីសម្រេច ឬ សេចក្តីណែនាំរបស់និយ័តករទូរគមនាគមន៍កម្ពុជា។

ប្រការ៦ .–

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសរួម និងកម្រងសេវាសាធារណៈ ដែលជាឧបសម្ព័ន្ធនៃប្រកាសរួមនេះ ព្រមទាំងទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិក ដែលផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា ឬ ប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬ ប្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

ប្រការ៧ .–

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវរៀបចំទីកន្លែងជាក់លាក់ដែលមានលក្ខណៈជាច្រកចេញចូលតែមួយ និងមានមន្ត្រីប្រចាំការរៀងរាល់ម៉ោងធ្វើការ សម្រាប់ការបម្រើសេវាជូនអតិថិជនឱ្យបានល្អប្រសើរ។ ទន្ទឹមនឹងនេះ និយ័តករទូរគមនាគមន៍កម្ពុជា ក៏ត្រូវពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្តល់សេវាសាធារណៈ ឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព។

ប្រការ៨ .–

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំលើការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

ប្រការ៩ .–

អនុញ្ញាតឱ្យនិយ័តករទូរគមនាគមន៍កម្ពុជា ប្រើប្រាស់ចំណូលប្រមូលបានពីកម្រៃសេវាសាធារណៈ សម្រាប់ការចំណាយលើកិច្ចដំណើរការរបស់ខ្លួន ស្របតាមគោលការណ៍ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រការ១០ ._

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវធ្វើរបាយការណ៍ចំណូល ចំណាយប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ១១ ._

កម្រងសេវាសាធារណៈដូចមានចែងក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

ប្រការ១២ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១៣ ._

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងនិយ័តករទូរគមនាគមន៍កម្ពុជា ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៨ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១៨

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ត្រាំ អ៊ីវតឹក

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ជូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

តារាងខ្ទមសម្គ័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ.ជ.ប.ត.ប.....សហវ.ប្រក ចុះថ្ងៃទី.....ខែ.....ឆ្នាំ២០១៨

ស្តីពីការផ្តល់សេវាសាធារណៈដោយនិយ័តករទូរគមនាគមន៍កម្ពុជា

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា		រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
			ឯកតាគិត	ទឹកប្រាក់ (រៀល)		
	I.	**ការផ្តល់លិខិតអនុញ្ញាត**				
១	១	បញ្ជាក់ការនាំចូល ការនាំចេញ ការផ្គត់ផ្គង់ និងការចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍	លិខិតអនុញ្ញាត	៤00.000	១0ថ្ងៃ	0១លើក
	២	ការបើកអាជីវកម្មសាលបម្រើសេវាអ៊ីនធីណិតកាហ្វេ នៅក្នុងរាជធានីភ្នំពេញ				
២		- ទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬ ប្តូរទីតាំង	ពាក្យស្នើសុំ	២0.000	១0ថ្ងៃ	0១លើក
៣		- ទទួល និងពិនិត្យពាក្យស្នើសុំបន្តសុពលភាព	ពាក្យស្នើសុំ	មិនគិតថ្លៃ		0១លើក
៤		- លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម	លិខិតអនុញ្ញាត	១00.000		0១ឆ្នាំ
	៣	ការបើកលក់ និង/ឬ ជួសជុលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ នៅក្នុងរាជធានីភ្នំពេញ				
៥		- ទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬ បន្តសុពលភាព ឬ ប្តូរទីតាំង	ពាក្យស្នើសុំ	២0.000	១0ថ្ងៃ	0១លើក
៦		- លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម	លិខិតអនុញ្ញាត	២00.000		0១ឆ្នាំ
	៤	ការបោះពុម្ពផ្សាយសៀវភៅលេខទូរគមនាគមន៍				
៧		- ទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬ បន្តសុពលភាព ឬ ប្តូរទីតាំង	ពាក្យស្នើសុំ	៤0.000	១0ថ្ងៃ	0១លើក
៨		- លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម	លិខិតអនុញ្ញាត	២0.000.000		0១ឆ្នាំ
	៥	ការចុះឈ្មោះប្រើប្រាស់គេហទំព័រ (.kh)				

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា		រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សញ្ញាណភាព
			ឯកតាគិត	ទឹកប្រាក់ (រៀល)		
៩		- ទទួល និងពិនិត្យពាក្យស្នើសុំចុះឈ្មោះគេហទំព័រ (.kh) ថ្មីឬ ស្នើសុំប្តូរ Name Server និង IP Address ឬ ស្នើសុំប្តូរព័ត៌មាននៅក្នុងពាក្យស្នើសុំចុះឈ្មោះគេហទំព័រ	គេហទំព័រ	៤0.000	១0ថ្ងៃ	0១លើក
១0		- ទទួល និងពិនិត្យពាក្យស្នើសុំភ្ជាប់ការប្រើប្រាស់គេហទំព័រឡើងវិញ	គេហទំព័រ	៤0.000		
១១		- ទទួល ពិនិត្យពាក្យស្នើសុំ និងផ្តល់លិខិតអនុញ្ញាតបញ្ឈប់ការប្រើប្រាស់គេហទំព័រ	គេហទំព័រ	មិនគិតថ្លៃ		
	៦	ការចុះឈ្មោះប្រើប្រាស់គេហទំព័រ (.gov.kh) សម្រាប់ស្ថាប័នរដ្ឋ				
១២		- ទទួល និងពិនិត្យពាក្យស្នើសុំចុះឈ្មោះគេហទំព័រ (.gov.kh) ថ្មី ឬ ស្នើសុំប្តូរ Name Server និង IP Address ឬ ស្នើសុំប្តូរព័ត៌មានគេហទំព័រ	គេហទំព័រ	មិនគិតថ្លៃ	១0ថ្ងៃ	0១លើក
១៣		- ទទួល និងពិនិត្យពាក្យស្នើសុំភ្ជាប់ការប្រើប្រាស់គេហទំព័រឡើងវិញ	គេហទំព័រ	មិនគិតថ្លៃ		
១៤		- ទទួល ពិនិត្យពាក្យស្នើសុំ និងផ្តល់លិខិតអនុញ្ញាតបញ្ឈប់ការប្រើប្រាស់គេហទំព័រ	គេហទំព័រ	មិនគិតថ្លៃ		
	៧	ការស្នើសុំប្រើប្រាស់លេខទូរស័ព្ទចល័ត អចល័ត និងលេខកូដទូរគមនាគមន៍ផ្សេងៗទៀត				
១៥		- ការស្នើសុំក្បាលលេខថ្មីនៃលេខទូរស័ព្ទចល័ត	ក្បាលលេខ	៤00.000	១0ថ្ងៃ	អចិន្ត្រៃយ៍
១៦		- ការស្នើសុំប្តូកថ្មីនៃលេខទូរស័ព្ទអចល័ត	ប្តូកលេខ	៤0.000	១0ថ្ងៃ	អចិន្ត្រៃយ៍
១៧		- ការស្នើសុំលេខកូដខ្ចីសម្រាប់សេវាគ្រាអាសន្ន	លិខិតអនុញ្ញាត	មិនគិតថ្លៃ	១0ថ្ងៃ	អចិន្ត្រៃយ៍

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា		រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	
			ឯកតាគិត	ទឹកប្រាក់ (រៀល)		
១៨		- ការស្នើសុំលេខកូដទូរគមនាគមន៍ផ្សេងៗទៀត	កូដ	៤០.000	១០ថ្ងៃ	អតិបរិមា
១៩		- ការស្នើសុំបង្វែរក្បាលលេខទូរស័ព្ទចល័តជូន ន.ទ.ក. វិញ	ក្បាលលេខ	មិនគិតថ្លៃ	១០ថ្ងៃ	
២០		- ការស្នើសុំបង្វែរប្លុកលេខទូរស័ព្ទអចល័តជូន ន.ទ.ក. វិញ	ប្លុកលេខ	មិនគិតថ្លៃ	១០ថ្ងៃ	
២១		- ការស្នើសុំបង្វែរលេខកូដទូរគមនាគមន៍ជូន ន.ទ.ក. វិញ	លិខិតអនុញ្ញាត	មិនគិតថ្លៃ	១០ថ្ងៃ	-
	៨	ការផ្តល់កិច្ចអន្តរាគមន៍លើការប្តឹងតវ៉ា÷				
២២		- រវាងអតិថិជន និងប្រតិបត្តិករ	ករណី	មិនគិតថ្លៃ	៣០ថ្ងៃ	-
២៣		- រវាងប្រតិបត្តិករ និងប្រតិបត្តិករ	ករណី	៤.000.000	៣០ថ្ងៃ	-
	៩	ការផ្តល់កិច្ចអន្តរាគមន៍សម្របសម្រួលលើការឆ្លងរំខាននៃការប្រើប្រាស់ប្រេកង់ស៊ីវិទ្យុ				
		ក. ប្រតិបត្តិករទូរគមនាគមន៍				
២៤		- រាជធានីភ្នំពេញ	ករណី	មិនគិតថ្លៃ	១៥ថ្ងៃ	-
២៥		- ខេត្ត	ករណី	មិនគិតថ្លៃ	២០ថ្ងៃ	-
		ខ. ប្រតិបត្តិករសោតទស្សន៍				
២៦		- រាជធានីភ្នំពេញ	ករណី	មិនគិតថ្លៃ	១០ថ្ងៃ	-
២៧		- ខេត្ត	ករណី	មិនគិតថ្លៃ	១៥ថ្ងៃ	-
		គ. អ្នកប្រើប្រាស់វិទ្យុទាក់ទង				
២៨		- រាជធានីភ្នំពេញ	ករណី	មិនគិតថ្លៃ	០៧ថ្ងៃ	-
២៩		- ខេត្ត	ករណី	មិនគិតថ្លៃ	១៥ថ្ងៃ	-
		ឃ. ក្រសួង ស្ថាប័នរដ្ឋ អង្គការ និងស្ថានទូត				

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា		រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	
			ឯកតាគិត	ទឹកប្រាក់ (រៀល)		សុពលភាព
៣០		- រាជធានីភ្នំពេញ	ករណី	មិនគិតថ្លៃ	១០ថ្ងៃ	-
៣១		- ខេត្ត	ករណី	មិនគិតថ្លៃ	១៥ថ្ងៃ	
	១០	លិខិតអនុញ្ញាតសាងសង់បង្គោលអង់តែន ដែលស្របតាមលក្ខណបច្ចេកទេសដែនអេឡិចត្រូម៉ាញេទិច សម្រាប់ផ្តល់សេវាទូរគមនាគមន៍ និងវិទ្យុគមនាគមន៍ដទៃទៀត				
៣២		- រាជធានីភ្នំពេញ	បង្គោលអង់តែន	មិនគិតថ្លៃ	១០ថ្ងៃ	អចិន្ត្រៃយ៍
៣៣		- ខេត្ត	បង្គោលអង់តែន	មិនគិតថ្លៃ	១៥ថ្ងៃ	អចិន្ត្រៃយ៍
	II. **ការផ្តល់វិញ្ញាបនបត្រ**					
	១១	ការទទួលស្គាល់គុណវុធិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍				
៣៤		- ទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬ បន្តសុពលភាព ឬ ប្តូរទីតាំង ឬ ប្តូរព័ត៌មាន	ពាក្យស្នើសុំ	៨០.000	១៥ថ្ងៃ	០១លើក
៣៥		- ផ្តល់វិញ្ញាបនបត្រ	វិញ្ញាបនបត្រ	១.២00.000	-	០២ឆ្នាំ
	១២	ការទទួលស្គាល់យថាប្រភេទនៃគ្រឿងបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍				
៣៦		- ទទួល និងពិនិត្យពាក្យស្នើសុំ	ពាក្យស្នើសុំ	៨០.000	១៥ថ្ងៃ	០១លើក
៣៧		- ផ្តល់វិញ្ញាបនបត្រចំពោះទូរស័ព្ទចល័តគ្រប់ប្រភេទ	ម៉ូដែល	៨.000.000	-	អចិន្ត្រៃយ៍
៣៨		- ផ្តល់វិញ្ញាបនបត្រចំពោះទូរស័ព្ទអចល័តគ្រប់ប្រភេទ	ម៉ូដែល	៦.000.000	-	អចិន្ត្រៃយ៍
៣៩		- ផ្តល់វិញ្ញាបនបត្រចំពោះទូរសារ ឬ ម៉ូដេមគ្រប់ប្រភេទ	ម៉ូដែល	៦.000.000	-	អចិន្ត្រៃយ៍
៤0		- ផ្តល់វិញ្ញាបនបត្រចំពោះបមាណី (PABX)	ម៉ូដែល	៦.000.000	-	អចិន្ត្រៃយ៍
៤១		- ផ្តល់វិញ្ញាបនបត្រចំពោះគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ផ្សេងទៀត	ម៉ូដែល	៤.000.000	-	អចិន្ត្រៃយ៍
	១៣	ការស្នើសុំកែសម្រួលវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ (មិនរួមបញ្ចូលការបន្ថែម ឬ កែសម្រួលផ្នែកណាមួយនៃគ្រឿងសម្ភារបរិក្ខារ)				

ច្បាប់ស្តីពីការទូរគមនាគមន៍ ជាធម្មតា ២០១៥ ច្បាប់ស្តីពីការ ១០ ១ ២០១ ២ ១ ២ ១ ២

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា		រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	
			ឯកតាគិត	ទឹកប្រាក់ (រៀល)		
៤២		- ទទួល និងពិនិត្យពាក្យស្នើសុំ	ពាក្យស្នើសុំ	៨០.000	១៥ថ្ងៃ	០១លើក
៤៣		- ផ្តល់វិញ្ញាបនបត្រ	ម្តងដែល	៤00.000		០១ដង
	III. **ការពិនិត្យពាក្យស្នើសុំដើម្បីបំពេញប្រតិបត្តិការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ឬ សេវាទូរគមនាគមន៍ (មុនផ្តល់អាជ្ញាប័ណ្ណប្រតិបត្តិការ)**					
៤៤	១៤	ហេដ្ឋារចនាសម្ព័ន្ធ និងសេវាថ្មី ឬ កែប្រែ ឬ ផ្ទេរ ឬ បូកបញ្ចូលគ្នា ឬ បន្ត	អាជ្ញាប័ណ្ណ	៤.000.000	៦០ថ្ងៃ	៣០ឆ្នាំ
៤៥	១៥	ហេដ្ឋារចនាសម្ព័ន្ធ និងសេវាមានដែនកំណត់ថ្មី ឬ កែប្រែ ឬ ផ្ទេរ ឬ បូកបញ្ចូលគ្នា ឬ បន្ត	អាជ្ញាប័ណ្ណ	៤.000.000	៦០ថ្ងៃ	៣០ឆ្នាំ
៤៦	១៦	សេវាទូរគមនាគមន៍ថ្មី ឬ កែប្រែ ឬ ផ្ទេរ ឬ បូកបញ្ចូលគ្នា ឬ បន្ត	អាជ្ញាប័ណ្ណ	២.000.000	៣០ថ្ងៃ	១៥ឆ្នាំ
៤៧	១៧	ផ្តល់សេវាបន្ថែមក្រោមវិសាលភាពនៃអាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ និងសេវា	បណ្តាញ/សេវា	២.000.000	៦០ថ្ងៃ	០១ដង
៤៨	១៨	ផ្តល់សេវាបន្ថែមក្រោមវិសាលភាពនៃអាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ និងសេវាមានដែនកំណត់	បណ្តាញ/សេវា	២.000.000	៦០ថ្ងៃ	០១ដង
៤៩	១៩	ផ្តល់សេវាបន្ថែមក្រោមវិសាលភាពនៃអាជ្ញាប័ណ្ណសេវាទូរគមនាគមន៍	បណ្តាញ/សេវា	១.000.000	៣០ថ្ងៃ	០១ដង
	IV. **ការពិនិត្យពាក្យស្នើសុំ និងពិនិត្យបរិក្ខារវិទ្យុគមនាគមន៍ (មុនផ្តល់អាជ្ញាប័ណ្ណប្រេកង់ស៍)**					
៥0	២0	វិទ្យុប្រភេទ MF	ពាក្យស្នើសុំ/គ្រឿង	៤0.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៥១	២១	វិទ្យុប្រភេទ HF	ពាក្យស្នើសុំ/គ្រឿង	៤0.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៥២	២២	វិទ្យុប្រភេទ VHF សម្រាប់អានុភាពផ្សាយគ្រប់កម្រិត នៅរាជធានីភ្នំពេញ និងកម្រិតអនុភាពផ្សាយលើសពី៦0 Watt នៅតាមបណ្តាខេត្ត	ពាក្យស្នើសុំ/គ្រឿង	៣0.000	១៥ថ្ងៃ	អចិន្ត្រៃយ៍

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា		រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ)	
			ឯកតាគិត	ទឹកប្រាក់ (រៀល)		
៥៣	២៣	វិទ្យុប្រភេទ UHF សម្រាប់គ្រប់កម្រិតអានុភាពផ្សាយ នៅរាជធានីភ្នំពេញ និងកម្រិតអនុភាពផ្សាយលើសពី៦០ Watt នៅតាមបណ្តាខេត្ត	ពាក្យស្នើសុំ/ គ្រឿង	៣០.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៥៤	២៤	វិទ្យុផ្សាយសំឡេងគ្រប់ប្រភេទ	ពាក្យស្នើសុំ/ គ្រឿង	៣២០.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៥៥	២៥	ទូរទស្សន៍គ្រប់ប្រភេទ	ពាក្យស្នើសុំ/ គ្រឿង	៣២០.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៥៦	២៦	វិទ្យុប្រភេទ Mobile Cellular Phone, Wireless Fixed Phone	ពាក្យស្នើសុំ/ គ្រឿង	៦00.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៥៧	២៧	វិទ្យុ ប្រព័ន្ធអ៊ីនធីណេត ISP	ពាក្យស្នើសុំ/ គ្រឿង	៦00.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៥៨	២៨	វិទ្យុម៉ៃក្រូវ៉េវ (Microwave Link)	ពាក្យស្នើសុំ/ គ្រឿង	៣២០.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៥៩	២៩	វិទ្យុ ប្រភេទ Satellite Broadband Internet (SBI)	ពាក្យស្នើសុំ/ គ្រឿង	៦00.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៦0	៣0	វិទ្យុសម្រាប់ទំនាក់ទំនងក្នុងករណីមានការអនុញ្ញាតពិសេស	ពាក្យស្នើសុំ/ គ្រឿង	១២0.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៦១	៣១	វិទ្យុប្រភេទ VSAT សម្រាប់សំឡេង ឬ ទិន្នន័យ(ប្រើប្រាស់ផ្ទាល់ខ្លួន)	ពាក្យស្នើសុំ/ គ្រឿង	៦00.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៦២	៣២	វិទ្យុប្រភេទ VSAT សម្រាប់សំឡេង ឬ ទិន្នន័យ(សម្រាប់ប្រតិបត្តិករ)	ពាក្យស្នើសុំ/ គ្រឿង	៦00.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៦៣	៣៣	វិទ្យុប្រភេទ VSAT សម្រាប់បញ្ជូនរូបភាពទូរទស្សន៍ (ព្រឹត្តិការណ៍ពិសេស)	ពាក្យស្នើសុំ/ គ្រឿង	៦00.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៦៤	៣៤	វិទ្យុប្រភេទ VSAT សម្រាប់បញ្ជូនរូបភាពទូរទស្សន៍ ក្នុង ឬ ក្រៅប្រទេស	ពាក្យស្នើសុំ/ គ្រឿង	៦00.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៦៥	៣៥	វិទ្យុប្រភេទអាម៉ាទ័រ (AMATEUR)	ពាក្យស្នើសុំ/ គ្រឿង	៦0.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៦៦	៣៦	វិទ្យុប្រភេទអ៊ីនម៉ាសាត ចល័ត អចល័ត ឬ តាំងជាប់នៅលើនាវា	ពាក្យស្នើសុំ/ គ្រឿង	៥២0.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៦៧	៣៧	វិទ្យុប្រភេទអ៊ីនម៉ាសាត ចុះឈ្មោះនៅបរទេស ហើយនាំចូលមកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា	ពាក្យស្នើសុំ/ គ្រឿង	៣២0.000	១៥ថ្ងៃ	អចិន្ត្រៃយ៍

លេខរៀងចំនួនសេវា		បរិយាយ	តម្លៃសេវា		រយៈពេលកំណត់សម្រាប់នៃការផ្តល់សេវា (ថ្ងៃធ្វើការ)	សុពលភាព
			ឯកតាគិត	ទឹកប្រាក់ (រៀល)		
៦៨	៣៨	វិទ្យុប្រភេទ Satellite Phone	ពាក្យស្នើសុំ/គ្រឿង	៣២០.000	១៥ថ្ងៃ	អចិន្ត្រៃយ៍
៦៩	៣៩	វិទ្យុប្រើប្រាស់ប្រេ្វកង់ស៍ប្រដប៉ែនលើយន្តហោះឆ្លងកាត់ផ្ទៃអាកាសកម្ពុជា	ពាក្យស្នើសុំ/គ្រឿង	៣២០.000	១៥ថ្ងៃ	អចិន្ត្រៃយ៍

<u>កំណត់សម្គាល់</u> : ១. ការផ្តល់លិខិតអនុញ្ញាត សម្រាប់ការបើកអាជីវកម្មសាលបម្រើសេវាអ៊ីនធឺណិតកាហ្វេ និងការបើកលក់ និង/ឬ ជួសជុលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ នៅតាមបណ្តាខេត្ត ស្ថិតក្នុងសមត្ថកិច្ចរបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត

២. ការពិនិត្យពាក្យស្នើសុំ និងការពិនិត្យបរិក្ខារវិទ្យុគមនាគមន៍ សម្រាប់ការផ្តល់លិខិតអនុញ្ញាតប្រើប្រាស់ប្រេ្វកង់ស៍វិទ្យុនៅតាមបណ្តាខេត្ត ចំពោះឧបករណ៍ផ្សាយមានអានុភាពក្រោម ៦0 Watt ស្ថិតក្នុងសមត្ថកិច្ចរបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត

៣. ចំពោះការផ្តល់លិខិតអនុញ្ញាត និងវិញ្ញាបនបត្រសម្រាប់ឆ្នាំដំបូង ការយកកម្រៃសេវាត្រូវគិតតាមរយៈពេលនៅសល់ក្នុងឆ្នាំ យោងតាមកាលបរិច្ឆេទចុះហត្ថលេខារបស់ និយ័តករទូរគមនាគមន៍កម្ពុជាដែលកំណត់ដូចខាងក្រោម ÷

- រយៈពេលនៅសល់មិនលើសពី ៦ខែ ត្រូវយកកម្រៃសេវាស្មើនឹង ៥0% (ហាសិបភាគរយ) នៃតម្លៃសេវាប្រចាំឆ្នាំ
- រយៈពេលនៅសល់លើសពី ៦ខែ ត្រូវយកកម្រៃសេវាស្មើនឹងតម្លៃសេវាប្រចាំឆ្នាំ។

ខ្លឹមសារ ១០០ ១ ១ ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៥០៣.....សហវ.....

ប្រកាសរួមក្រសួង
ស្តីពី
ការតែងតាំងរដ្ឋទេយ្យការចំណូល និងរដ្ឋទេយ្យការចំណូលរង
នៅវិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល

ទេសរដ្ឋមន្ត្រី	**រដ្ឋមន្ត្រី**
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	**ក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នរ/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រ៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការប្រែក្លាយវិទ្យាស្ថានជាតិសុខភាពសាធារណៈ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រ៤៤ មាត្រ៤៥ មាត្រា ៤៦ និងមាត្រា ៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសរបេ២ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវិទ្យាស្ថានជាតិសុខភាពសាធារណៈនៃក្រសួងសុខាភិបាល

ស ម្រេ ច

ប្រការ១._

ត្រូវបានតែងតាំងរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង របស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល ដែលមានសមាសភាពដូចខាងក្រោម ÷

១-លោកស្រី **ហាស សុដ្ឋារី**	ឋានៈ:ប្រធានផ្នែកបេឡា	ជារដ្ឋទេយ្យករចំណូល
២-លោកស្រី **ជា សុតន្ត្រា**	ឋានៈ:មន្ត្រី	ជារដ្ឋទេយ្យករចំណូលរង

ប្រការ២._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣._

នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ វិទ្យាស្ថានជាតិសុខភាពសាធារណៈ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ព្រមទាំងសាមីខ្លួន ជួចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ១៥ ១០ ១ ១ ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងរដ្ឋទេយ្យការចំណូល និងរដ្ឋទេយ្យការចំណូលរង
នៅសាលាជាតិកសិកម្មកំពង់ចាម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ទេសរដ្ឋមន្ត្រី	**រដ្ឋមន្ត្រី**
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/ នស/ ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិក.មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា ៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្ય សាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃ គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់ គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាល ហិរញ្ញវត្ថុជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកា គណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៤៥៥ សហវ.អថ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការប្រគល់ភាពឯកិច្ច ប្រមូល ចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (សាលាជាតិកសិកម្មកំពង់ចាម)

សម្រេច

ប្រការ១.

ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានសមាសភាព ខាងក្រោម÷

- លោកស្រី **ឃុន សុខលីន** អនុប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ នៃសាលាជាតិកសិកម្ម កំពង់ចាម ជារដ្ឋទេយ្យករចំណូលនៅសាលាជាតិកសិកម្មកំពង់ចាម។
- កញ្ញា **ញ៉ ឆុណា** មន្ត្រីការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ នៃសាលាជាតិកសិកម្មកំពង់ចាម ជារដ្ឋទេយ្យករចំណូលរងនៅសាលាជាតិកសិកម្មកំពង់ចាម។

ប្រការ២.

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣.

នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ នាយកសាលាជាតិកសិកម្មកំពង់ចាម ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ១០ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១៨

នេសរដ្ឋមន្ត្រី	រដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គបណ្ឌិតសភាចារ្យ ហ៊ុន ម៉ានីត	វេង សាខុន

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....សហវ.....

ប្រកាស
ស្តីពី
ការតែងតាំងគណៈនេយ្យករ
ប្រចាំនៅមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល នៃក្រសួងសុខាភិបាល

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ផ្ទះលេខ ៤២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ស្តីពីការប្រែក្លាយមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា ៤៦ និងមាត្រា ៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់ គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ ._

ត្រូវបានតែងតាំងលោក **លី អារីហ្ជីន** ជាគណនេយ្យករ ប្រចាំនៅមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល បន្ថែមលើមុខងារបច្ចុប្បន្ន។

ប្រការ២ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ ._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែកក្កដា ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ខ្នាសា ឆ្នាំ ២០១៨

អគ្គបណ្ឌិតសភាចារ្យ ង្គួន ម៉ាឌ្ឍមុនីរ៉ូ

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ក្រសួងសុខាភិបាល
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី